**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ១៥២២ ព.ណ.-កប

ថ្ងៃសុក្រ ១០រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ ២០២២

# សេចក្ដីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ ឧកញ៉ា លោក-លោកស្រីជាម្ចាស់សហគ្រាស ផលិតករ សេវាករ ពាណិជ្ជករ និងសាធារណជនទូទៅដែលកំពុងធ្វើធុរកិច្ចលើវិស័យគ្រឿងអលង្ការ និងត្បូងថ្មមានតម្លៃឲ្យបានជ្រាបថា៖ ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រថៃឡង់ដ៍ នឹងរៀបចំពិព័រណ៍គ្រឿងអលង្ការ និងត្បូងថ្មមានតម្លៃ បាងកក លើកទី៦៧ **"The 67th Bangkok Gems & Jewelry Fair"** ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី០៧-១១ ខែកញ្ញា ឆ្នាំ២០២២ នៅមជ្ឈមណ្ឌលតាំងពិព័រណ៍ IMPACT ទីក្រុងបាងកក ប្រទេសថៃឡង់ដ៍។ នេះជាព្រឹត្តិការណ៍ពាណិជ្ជកម្មលើវិស័យគ្រឿងអលង្ការ និងត្បូងថ្មមានតម្លៃកម្រិតអន្តរជាតិដ៏ធំ និងធ្លាប់ទទួលបានជោគជ័យអស់រយៈពេល ៦៦ លើករួចមកហើយ ដោយមានអ្នកតាំងពិព័រណ៍ និងអ្នកទស្សនាមកពីគ្រប់តំបន់ជុំវិញពិភពលោកបានមកចូលរួម។

ក្រសួងពាណិជ្ជកម្ម ក្នុងនាមអ្នកសម្របសម្រួលការងារពិព័រណ៍ពាណិជ្ជកម្ម ជូនគណៈកម្មការរៀបចំពិព័រណ៍របស់ប្រទេសថៃឡង់ដ៍ សូមអញ្ជើញ ឧកញ៉ា លោក-លោកស្រី ជាម្ចាស់សហគ្រាសគ្រឿងអលង្ការ និងត្បូងថ្មមានតម្លៃ ដែលមានចំណាប់អារម្មណ៍ចង់ចូលរួមក្នុងព្រឹត្តិការណ៍ពាណិជ្ជកម្មនេះ ដើម្បីផ្លាស់ប្ដូរកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរលើវិស័យគ្រឿងអលង្ការ និងត្បូងថ្មមានតម្លៃ សូមទាក់ទងមន្ត្រីសម្របសម្រួល **កញ្ញា តុង រីតា** នាយកដ្ឋានកិច្ចការពិព័រណ៍ នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម តាមរយៈអាសយដ្ឋាន ដីឡូត៍លេខ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ តាមរយៈទូរស័ព្ទលេខ ០៨៧ ៧៥៥ ៥៥១ អ៊ីម៉ែល **ritatong19@gmail.com** ឲ្យបានយ៉ាងបំផុតត្រឹមថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២ ជាកំណត់។ ង.រស

**សូមអរគុណ!**

ក្រសួងពាណិជ្ជកម្ម